**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

លេខ......០១២......អ. ស. ហ.ប្រ.ក.

# ប្រកាស
# ស្តីពី
# ការបើកសាខារបស់បរធនបាល

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបរធនបាលកិច្ច
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២២/០០៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

#១៦៨F ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ
#168F, St. 598, Chrang Chamres 1, Russei Keo, Phnom Penh
Website: fsa.gov.kh, Telegram: t.me/fsacambodia
ទូរស័ព្ទ: (+៨៥៥) ២៣ ៩៩០ ៧០០
Phone: (+855) 23 990 700
info@fsa.gov.kh

- បានឃើញអនុក្រឹត្យលេខ ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការចុះបញ្ជីបរធនបាលកិច្ច
- បានឃើញប្រកាសលេខ ០០៣ អ.ស.ហ.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច
- បានឃើញប្រកាសលេខ ០៦៧ អ.ស.ហ.ប្រក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីកាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល
- បានទទួលការឯកភាពពីក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារក្នុងសម័យប្រជុំនាថ្ងៃទី៦ ខែមករា ឆ្នាំ២០២៦

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ការអនុញ្ញាតបើកសាខាបរធនបាល ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ក្នុងវិស័យបរធនបាលកិច្ច។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះបរធនបាល ដែលទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាតពីនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ច នៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

វាក្យសព្ទដែលប្រើក្នុងប្រកាសនេះ មាននិយមន័យដូចខាងក្រោម៖

**ក្រុមហ៊ុនដើម** សំដៅដល់ក្រុមហ៊ុនបរធនបាល ឬប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច ដែលទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាតពី **ន.ប.ធ.** ឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ច និងជាក្រុមហ៊ុនចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា។

**សាខា** សំដៅដល់ទីកន្លែងផ្សេងពីទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនដើម សម្រាប់ធ្វើអាជីវកម្មក្នុងក្របខ័ណ្ឌអាជ្ញាបណ្ណ ឬការអនុញ្ញាតរបស់ក្រុមហ៊ុនដើម ហើយពុំមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ។

## ជំពូកទី២

## ការអនុញ្ញាតបើកសាខាបរធនបាល

**ប្រការ៤.-**

គ្មានក្រុមហ៊ុនដើមណាមួយអាចបើកសាខាបរធនបាល ឬគ្មានបុគ្គលណាមួយអាចតាំងខ្លួនជាសាខាបរធនបាលបានទេ លើកលែងតែក្រុមហ៊ុនដើម ឬបុគ្គលនោះទទួលបានការអនុញ្ញាតជាមុនពី **ន.ប.ធ.**។

ការអនុញ្ញាតបើកសាខាបរធនបាល មានសុពលភាពអនុលោមទៅតាមសុពលភាពនៃអាជ្ញាបណ្ណ ឬ ការអនុញ្ញាតរបស់ក្រុមហ៊ុនដើម។

**ប្រការ៥.-**

ក្រុមហ៊ុនដើមដែលស្នើសុំការអនុញ្ញាតបើកសាខា ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- ចុះបញ្ជីសាខាក្នុងបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា។

២- ចុះបញ្ជីពន្ធដារសម្រាប់សាខាអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

៣- មានរចនាសម្ព័ន្ធគ្រប់គ្រងសាខាដែលកំណត់ច្បាស់លាស់ពីការទទួលខុសត្រូវ និងភារកិច្ចដែលអាចធានាបាននូវតម្លាភាព ប្រសិទ្ធភាព គណនេយ្យភាព និងអភិបាលកិច្ចសាជីវកម្មល្អ។

៤- មានទីតាំងសាខាសមស្រប និងមានបំពាក់បរិក្ខារគ្រប់គ្រាន់សម្រាប់ធ្វើអាជីវកម្ម។

៥- មានហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រាន់សម្រាប់សាខា។

៦- មានប្រព័ន្ធ និងគោលនយោបាយគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុងសមស្រប។

៧- ធានាឱ្យបាននូវនីតិវិធីសមស្របក្នុងការដោះស្រាយការតវ៉ារបស់អតិថិជន និងវិវាទរវាងបុគ្គលិក និងអតិថិជន។

៨- ត្រូវមានធនធានមនុស្ស ដូចខាងក្រោម៖

ក. ចំពោះក្រុមហ៊ុនបរធនបាល៖

- ត្រូវមាននាយកគ្រប់គ្រងសាខា ដែលត្រូវទទួលបានការទទួលស្គាល់គុណវុឌ្ឍិពី **ន.ម.ធ.** ដោយត្រូវដាក់ពាក្យស្នើសុំមក **ន.ម.ធ.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយ **ន.ម.ធ.** ព្រមទាំងបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

- មានលក្ខណសម្បត្តិ និងអត្តចរិតល្អ
- ជាសមត្ថជននិងមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា
- មានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច ឬហិរញ្ញវត្ថុ ឬសញ្ញាបត្រផ្សេងៗទៀតដែលមានតម្លៃប្រហាក់ប្រហែលក្នុងវិស័យហិរញ្ញវត្ថុ និងត្រូវមានចំណេះដឹងនិងបទពិសោធការងារយ៉ាងតិច ៤ (បួន) ឆ្នាំក្នុងវិស័យបរធនបាលកិច្ច ឬហិរញ្ញវត្ថុ
- ផ្តល់លិខិតតែងតាំងពីក្រុមហ៊ុនដើម
- ចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡង ដែលរៀបចំដោយ **ន.ម.ធ.** ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **ន.ម.ធ.** ហើយលទ្ធផលប្រឡងមានសុពលភាព ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែល **ន.ម.ធ.** ប្រកាសលទ្ធផលប្រឡង។ បុគ្គលដាក់ពាក្យស្នើសុំ ត្រូវចូលរួមការអប់រំវិជ្ជាជីវៈបន្តដែលរៀបចំដោយ **ន.ម.ធ.** ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **ន.ម.ធ.** មុនពេលលទ្ធផលប្រឡងអស់សុពលភាព។
- មិនស្ថិតក្នុងស្ថានភាព ឬកាលៈទេសៈ ដូចមានចែងក្នុងចំណុច ក ដល់ ញ នៃកថាខណ្ឌទី២ នៃប្រការ១៦ នៃប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច។

- ត្រូវមានបរធនបាលរូបវន្តបុគ្គលនៃសាខាក្រុមហ៊ុនបរធនបាល ដែលត្រូវទទួលបានអាជ្ញាបណ្ណពី **ន.ម.ធ.**។ បុគ្គលដាក់ពាក្យស្នើសុំត្រូវមានបរធនបាលរូបវន្តបុគ្គលដាច់ដោយឡែកពីគ្នាទៅតាមប្រភេទបរធនបាលកិច្ច

នីមួយៗ និងត្រូវមានចំនួនបរធនបាលរូបវន្តបុគ្គលឱ្យមានសមាមាត្រទៅតាមទំហំប្រតិបត្តិការបរធនបាលកិច្ច របស់ខ្លួន។

ខ. ចំពោះប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច៖

- ត្រូវមាននាយកគ្រប់គ្រងសាខា និងប្រធានប្រតិបត្តិការ ដែលត្រូវទទួលបានការទទួលស្គាល់គុណវុឌ្ឍិពី **ន.ម.ធ.** ដោយត្រូវដាក់ពាក្យស្នើសុំមក **ន.ម.ធ.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយ **ន.ម.ធ.** ព្រមទាំងបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានលក្ខណសម្បត្តិ និងអត្តចរិតល្អ
- ជាសមត្ថជន និងមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា
- មានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច ឬហិរញ្ញវត្ថុ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែលក្នុងវិស័យហិរញ្ញវត្ថុ និងត្រូវមានចំណេះដឹង និងបទពិសោធការងារយ៉ាងតិច ៣ (បី) ឆ្នាំក្នុងវិស័យបរធនបាលកិច្ច ឬហិរញ្ញវត្ថុ
- ផ្តល់លិខិតតែងតាំងពីក្រុមហ៊ុនដើម
- ចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡង ដែលរៀបចំដោយ **ន.ម.ធ.** ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **ន.ម.ធ.** ហើយលទ្ធផលប្រឡងមានសុពលភាព ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែល **ន.ម.ធ.** ប្រកាសលទ្ធផលប្រឡង។ បុគ្គលដាក់ពាក្យស្នើសុំត្រូវចូលរួមការអប់រំវិជ្ជាជីវៈបន្ត ដែលរៀបចំដោយ **ន.ម.ធ.** ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **ន.ម.ធ.** មុនពេលលទ្ធផលប្រឡងអស់សុពលភាព។
- មិនស្ថិតក្នុងស្ថានភាព ឬកាលៈទេសៈ ដូចមានចែងក្នុងចំណុច ក ដល់ ញ នៃកថាខណ្ឌទី២ នៃប្រការ១៦ នៃប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច។

៩-លក្ខខណ្ឌផ្សេងទៀតតាមការកំណត់របស់ **ន.ម.ធ.**។

លក្ខខណ្ឌដូចមានចែងក្នុងចំណុចទី១ ដល់ចំណុចទី៧ ខាងលើ មិនត្រូវបានអនុវត្តចំពោះក្រុមហ៊ុនដើមដែលជាធនាគារពាណិជ្ជទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាតធ្វើជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ចទេ។

**ប្រការ៦.-**

ក្រុមហ៊ុនដើមដែលមានបំណងបើកសាខាបរធនបាល ត្រូវដាក់ពាក្យស្នើសុំទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ ដែលកំណត់ដោយ **ន.ម.ធ.**។

**ន.ម.ធ.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំអំពីការយល់ព្រម ឬការបដិសេធផ្តល់ការអនុញ្ញាត ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ ក្នុងរយៈពេលយ៉ាងយូរ ៦០ (ហុកសិប) ថ្ងៃ ដោយគិតចាប់ពីកាលបរិច្ឆេទដែល **ន.ម.ធ.** ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

**ប្រការ៧.-**

**ន.ម.ធ.** ត្រូវចាត់ចែងការចុះត្រួតពិនិត្យដល់ទីកន្លែង ដើម្បីផ្ទៀងផ្ទាត់ពាក្យស្នើសុំការអនុញ្ញាតបើកសាខាបរធនបាល និងដើម្បីធ្វើការត្រួតពិនិត្យនូវរាល់ព័ត៌មាន ទិន្នន័យ ឯកសារ និងប្រតិបត្តិការពាក់ព័ន្ធនឹងអាជីវកម្មនៅសាខានោះ។

**ប្រការ៨.-**

ក្រុមហ៊ុនដើមត្រូវចាប់ផ្តើមធ្វើប្រតិបត្តិការបរធនបាលកិច្ចនៅសាខាដែលទទួលបានការអនុញ្ញាត ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ខែ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលបានការអនុញ្ញាតបើកសាខាពី **ន.ម.ធ.**។

**ប្រការ៩.-**

ក្រុមហ៊ុនដើមត្រូវស្នើសុំការអនុញ្ញាតជាមុនពី **ន.ម.ធ.** ក្នុងករណីណាមួយ ដូចខាងក្រោម៖

១- ផ្លាស់ប្តូរ ឬតែងតាំងនាយកគ្រប់គ្រងសាខា និងប្រធានប្រតិបត្តិការ

២- ផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជីសាខា។

៣- ផ្លាស់ប្តូរបរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល រវាងក្រុមហ៊ុនដើមនិងសាខា ឬរវាងសាខានិងសាខា។

ករណីតំណែងនាយកគ្រប់គ្រងសាខា ឬប្រធានប្រតិបត្តិការនៅទំនេរ ក្រុមហ៊ុនដើមត្រូវជ្រើសរើសបេក្ខភាពថ្មីក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ។

ប្រសិនបើតំណែងបរធនបាលរូបវន្តបុគ្គលក្នុងសាខានៅទំនេរ ក្រុមហ៊ុនដើមត្រូវជ្រើសរើសបេក្ខភាពថ្មីក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ខែ ដោយគិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ។

**ប្រការ១០.-**

ក្រុមហ៊ុនដើមត្រូវធានាថា សាខាបរធនបាល ត្រូវធ្វើប្រតិបត្តិការដាច់ដោយឡែកពីគ្នា និងដាច់ដោយឡែកពីអាជីវកម្មផ្សេងទៀតដែលខ្លួនមាន ដោយត្រូវមានបរិក្ខារ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងធនធានមនុស្សដាច់ដោយឡែកពីគ្នា និងត្រូវមានរបាំងព័ត៌មានសមស្របនៅសាខានោះ។

**ប្រការ១១.-**

**ន.ម.ធ.** អាចព្យួរ ឬលុបចោលការអនុញ្ញាតបើកសាខាបរធនបាល ក្នុងករណីក្រុមហ៊ុនដើមស្នើសុំផ្អាក ឬឈប់ធ្វើប្រតិបត្តិការ ឬស្ថិតក្នុងស្ថានភាពណាមួយ ដូចខាងក្រោម៖

១- មិនអនុវត្តសេចក្តីសម្រេចដែលត្រូវឱ្យសងបំណុលមួយភាគ ឬទាំងស្រុង។

២- កំពុងស្ថិតក្នុងស្ថានភាពបច្ចេកទេស ឬហិរញ្ញវត្ថុទន់ខ្សោយ ឬកំពុងត្រូវរំលាយដោយគ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត ឬដោយការវិនិច្ឆ័យរបស់តុលាការទៅតាមមូលហេតុស្របច្បាប់។

៣- មិនអាចបន្តគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ។

**ប្រការ១២.-**

ក្រុមហ៊ុនដើមដែលមានបំណងបិទសាខាបរធនបាល ត្រូវស្នើសុំការអនុញ្ញាតជាមុន និងត្រូវបំពេញលក្ខខណ្ឌទៅតាមការកំណត់របស់ **ន.ម.ធ.**។

## ជំពូកទី៣
## កម្រៃសេវា

**ប្រការ១៣.-**

ក្រុមហ៊ុនដើមដែលបានដាក់ពាក្យស្នើសុំ ត្រូវបង់ថ្លៃពាក្យស្នើសុំ សោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃការអនុញ្ញាតបើកសាខា ទៅតាមកម្រៃដូចខាងក្រោម៖

១- ថ្លៃពាក្យស្នើសុំការអនុញ្ញាតបើកសាខា ចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុង ១ (មួយ) ច្បាប់

២- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ៦០០.០០០ (ប្រាំមួយរយពាន់) រៀល
៣- ថ្លៃការអនុញ្ញាតបើកសាខាក្នុង ១ (មួយ) សាខា៖
ក- សម្រាប់ប្រតិបត្តិករលើបរធនបាលកិច្ចសាធារណៈ ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។
ខ- សម្រាប់ប្រតិបត្តិករលើបរធនបាលកិច្ចពាណិជ្ជកម្ម ចំនួន ៤.០០០.០០០ (បួនលាន) រៀល សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។
គ- សម្រាប់ប្រតិបត្តិករលើបរធនបាលកិច្ចសង្គម ចំនួន ២.០០០.០០០ (ពីរលាន) រៀល សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។
ឃ- សម្រាប់ប្រតិបត្តិករលើបរធនបាលកិច្ចបុគ្គល ចំនួន ២.០០០.០០០ (ពីរលាន) រៀល សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

**ប្រការ១៤**.-

ក្រុមហ៊ុនដើម ត្រូវបង់សោហ៊ុយលើការស្នើសុំការអនុញ្ញាតលើការផ្លាស់ប្តូរ ឬការកែប្រែផ្សេងៗ ដូចខាងក្រោម៖

១- សោហ៊ុយសិក្សាសំណុំលិខិត ចំនួន ២០០.០០០ (ពីររយពាន់) រៀល សម្រាប់ការស្នើសុំផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជីសាខានីមួយៗ។
២- សោហ៊ុយសិក្សាសំណុំលិខិត ចំនួន ២០០.០០០ (ពីររយពាន់) រៀល សម្រាប់ការស្នើសុំផ្លាស់ប្តូរ ឬតែងតាំងនាយកគ្រប់គ្រងសាខា ឬប្រធានប្រតិបត្តិករ។
៣- សោហ៊ុយសិក្សាសំណុំលិខិត ចំនួន ២០០.០០០ (ពីររយពាន់) រៀល សម្រាប់ការស្នើសុំផ្លាស់ប្តូរទីតាំងបំពេញការងាររបស់បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនរវាងក្រុមហ៊ុនដើម និងសាខា ឬរវាងសាខា និងសាខា។

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត អនុលោមតាមប្រកាសនេះ មិនត្រូវបានប្រគល់ជូនបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីការស្នើសុំការអនុញ្ញាតបើកសាខា ការស្នើសុំផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជីសាខា ការស្នើសុំផ្លាស់ប្តូរ ឬការតែងតាំងនាយកគ្រប់គ្រងសាខា ប្រធានប្រតិបត្តិករ និងការស្នើសុំផ្លាស់ប្តូរទីតាំងបំពេញការងាររបស់បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុន ត្រូវបានបដិសេធក៏ដោយ។

## ជំពូកទី៤
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ១៥**.-

ក្រុមហ៊ុនដើមត្រូវអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងត្រូវទទួលខុសត្រូវលើកាតព្វកិច្ច និងរាល់សកម្មភាពរបស់សាខា។

**ប្រការ១៦**.-

ក្រុមហ៊ុនដើមត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **និ.ម.ធ.** ក្នុងករណីមានការកែប្រែឯកសារ ឬព័ត៌មានពាក់ព័ន្ធនឹងពាក្យស្នើសុំការអនុញ្ញាតបើកសាខា។

**ប្រការ១៧**.-

ក្រុមហ៊ុនដើមត្រូវបញ្ចូលព័ត៌មានពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្មសាខា ក្នុងរបាយការណ៍សមាយិក និងរបាយការណ៍ផ្សេងទៀតដែលត្រូវដាក់ជូនមក **និ.ម.ធ.** អនុលោមតាមប្រកាសស្តីពី កាតព្វកិច្ចផ្តល់របាយការណ៍

ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល និងប្រការ៤២ នៃប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច។

**ប្រការ១៨.-**

បន្ទាប់ពីទទួលបានការអនុញ្ញាតឱ្យបើកសាខាពី **ន.ម.ធ.** ក្រុមហ៊ុនដើមត្រូវបន្តគោរពតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ៥ និងត្រូវស្នើសុំការអនុញ្ញាតជាមុនពី **ន.ម.ធ.** មុននឹងធ្វើការផ្លាស់ប្តូរ ឬកែប្រែព័ត៌មានពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការអនុញ្ញាតអនុលោមតាមប្រកាសនេះ។

## ជំពូកទី៥
## ទណ្ឌកម្ម

**ប្រការ១៩.-**

មន្ត្រីអធិការកិច្ចបរធនបាលកិច្ចអាចចាត់វិធានការរដ្ឋបាល ចំពោះក្រុមហ៊ុនដើម ឬបុគ្គលដែលមិនអនុវត្តតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ/ការអនុញ្ញាត ដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលរងវិធានការរដ្ឋបាលណាមួយ ដូចខាងក្រោម៖

-ការព្រមាន

-ការដឹកនាំកែតម្រង់

-ការដាក់កំហិតលើអាជ្ញាបណ្ណ/ការអនុញ្ញាត

-ការដាក់កំហិតលើការចាត់ចែង គ្រប់គ្រង និង/ឬថែរក្សាទ្រព្យសម្បត្តិបរធនបាលកិច្ច

-ការព្យួរអាជ្ញាបណ្ណ/ការអនុញ្ញាត

-ការព្យួរ ឬបណ្តេញចេញពីមុខតំណែងនាយកសាខា បុគ្គលិកជាន់ខ្ពស់ និង/ឬបុគ្គលប្រព្រឹត្តល្មើស

-ការដកហូតអាជ្ញាបណ្ណ/ការអនុញ្ញាត។

**ប្រការ២០.-**

បែបបទ និងនីតិវិធីនៃការចាត់វិធានការរដ្ឋបាល និងការផាកពិន័យជាប្រាក់ ដូចមានចែងក្នុងជំពូកនេះ ត្រូវអនុលោមតាមប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល និងពិន័យអន្តរការណ៍។

បុគ្គលដែលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ដូចមានចែងក្នុងជំពូកនេះ អាចប្តឹងតវ៉ាតាមនីតិវិធីស្របតាមច្បាប់ស្តីពីបរធនបាលកិច្ច។

**ប្រការ២១.-**

វិធានការរដ្ឋបាល និងការផាកពិន័យដូចមានចែងក្នុងជំពូកនេះមិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌជាធរមាន និងដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ២២.-**

**ន.ម.ធ.** អាចចេញគោលការណ៍ណែនាំ អនុលោមតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ។

**ប្រការ២៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៤.-**

អគ្គលេខាធិការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អគ្គនាយកនៃនិយ័តករ ប្រធានអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១០កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមករាឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាព និងសមាសភាពក្រុមប្រឹក្សានៃ អ.ស.ហ. "ដើម្បីជូនជ្រាប"
- ដូចប្រការ ២៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ